# អត្ថបទសម្រាប់
# វគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំសម្រាប់យុវជនងាយរងគ្រោះ
# ដោយសារមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា



នៅព្រឹកថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៤ នៅសណ្ឋាគារ ហ្គ្រីន ផាលេស ( Green Palace Hotel) មានរៀបចំបើកវគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំវ័យក្មេងសម្រាប់ក្រុមងាយរងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។ វគ្គបណ្តុះបណ្តាលនេះ មានរយៈ ពេល ៥ ថ្ងៃ ចាប់ពីថ្ងៃទី ១១ ដល់ ១៥ ខែ សីហា ឆ្នាំ ២០១៤ រៀបចំដោយ បណ្តាញយុវជន ងាយរងគ្រោះដោយសារជំងឺអេដស៍នៅកម្ពុជា សហការណ៍ជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្រោមការ ឧបត្ថម្ភពី***អង្គការ យូណេស្កូ និងអង្គការ ខាណា*** ដោយមាន អ្នកចូលរួមប្រមាណជា៤០ នាក់ មកពីក្រុមយុវជនបុរសស្រឡាញ់បុរស យុវជនស្រីស្រស់ យុវជនបម្រើការ កន្លែង កម្សាន្តសប្បាយ យុវជនប្រើប្រាស់គ្រឿងញៀន និងយុវជនរស់នៅជាមួយមេរោគអេដស៍ និងជំងឺអេដស៍។




ថ្លែងក្នុងពិធីបើកវគ្គនេះ ឯកឧត្តម វេជ្ជបណ្ឌិត **តែង គន្ធី** អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានបញ្ជាក់ឱ្យដឹងថា បញ្ហាមេរោគអេដស៍ និងជំងឺអេដស៍នៅតែជាបញ្ហាដែលគួរឱ្យព្រួយបារម្ភដដែល នៅក្នុងប្រទេសកម្ពុជាបើទោះបីអត្រាឆ្លងរាលដាលនៃមេរោគអេដស៍បានធ្លាក់ចុះក៏ដោយ។ ឯកឧត្តម វេជ្ជបណ្ឌិតបានបន្ថែមថា តាមរយៈការសិក្សាក្នុងចំណោម យុវជនប្រឈមមុខខ្ពស់ឆ្នាំ ២០១០ របស់ក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញថាឥរិយាបថមួយចំនួន ដែលក្រុមយុវជនកំពុងតែប្រឈមរួមមាន ការប្រើប្រាស់ស្រោមអនាម័យជាមួយសង្សារនៅមានកម្រិតទាប ក្នុងនោះបុរសមានចំនួន **៦៨ %** និងស្រ្តី **៤៦%**។ មានស្រ្តីប្រមាណជា **៤៣%** និងបុរស **៣០%** មានរោគសញ្ញាកាមរោគ ដោយមិនបានទៅទទួលការព្យាបាល។ក្នុងរបាយការណ៍ក៏បានបង្ហាញថា **១២%** នៃស្រ្តីធ្លាប់មានផ្ទៃពោះ និង **៣៣%**ក្នុងចំណោមនោះធ្លាប់រំលូតកូន។

ជាងនេះទៀត តាមរយៈការសិក្សាថ្មីមួយក្នុងឆ្នាំ ២០១៤ ក្នុងទីក្រុងភ្នំពេញស្តីពីស្នេហា និងទំនាក់ទំនងផ្លូវភេទរបស់យុវវ័យ នៅក្នុងថ្ងៃ ទិវានៃសេចក្តីស្រឡាញ់ក៏បានបង្ហាញដែរថា យុវវ័យដែលមានដៃគូរ ឬគូរសង្សារ ហើយមានផែនការរួមភេទមានប្រមាណជា **១៥.៨%** ដែលក្នុងនោះដែរការមិនប្រើប្រាស់ស្រោមអនាម័យមានចំនួន **៣០.២%**។ មូលហេតុទាំងអស់នេះ ហើយដែលជាមូលហេតុចម្បងៗ បណ្តាលឱ្យយុវជនកម្ពុជាមានការប្រឈមទៅនឹងបញ្ហាសុខភាព ជាពិសេសការឆ្លងមេរោគអេដស៍។

ជាមួយនឹងការឆ្លើយតបទៅនឹងបញ្ហាទាំងនេះ រដ្ឋាភិ - បាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយថ្មីរបស់ការប្រយុទ្ធប្រឆាំងការរាលដាលមេរោគអេដស៍ដែលផ្តោតលើបញ្ហាយុវជន តាមរយៈការយកចិត្តទុកដាក់បន្ថែមទៀតលើការបង្កើនការផ្សព្វផ្សាយ ពង្រឹងសមត្ថភាព និងជំរុញការចូលរួមរបស់យុវ - ជន ជាពិសេសក្រុមងាយរងគ្រោះ។




លោក **ផង់ ចន្ថន** អ្នកសម្របសម្រួល វគ្គបណ្តុះនេះបានបញ្ជាក់ថា គោលបំណងសំខាន់សម្រាប់វគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំសម្រាប់យុវជនមកពីក្រុមងាយរងគ្រោះនេះ គឺដើម្បី បង្កើតនូវចំណេះដឹង ជំនាញ និងសមត្ថភាពផ្នែកភាពជាអ្នកដឹកនាំ និងការស្វែករកការទ្រដល់យុវជនងាយរងគ្រោះ ក្នុងការរួមចំណែកទប់ស្កាត់ការរាលដាលមេរោគអេដស៍នៅកម្ពុជាឱ្យកាន់តែមានប្រសិទ្ធភាព ។ លោកបានបន្ថែមថា វគ្គនេះនឹងអាចជួ ពង្រឹងសមត្ថភាពរបស់យុវជន និង ស្ថាប័នរបស់ពួកគេ ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រឈមឱ្យមានប្រសិទ្ធភាព ក៏ដូចជាធ្វើការផ្សារភ្ជាប់ប្រធានបទ និងវិធីសាស្រ្តពីវគ្គបណ្តុះបណ្តាល ចំពោះកម្មវិធីដែលកំពុងអនុវត្តផ្នែកភាពជាអ្នកដឹកនាំ និងការស្វែងរកការគាំទ្រ។

បើតាមរបាយការណ៍របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគបានបង្ហាញថា អត្រាឆ្លងមេរោគអេដស៍នៅក្នុងឆ្នាំ ២០១៤ នេះមានប្រមាណជា ០.៧ % ក្នុងចំណោមប្រជាជនអាយុចន្លោះពី ១៥ ទៅ ៤៩ ឆ្នាំ ហើយក្រុមគោលដៅដែលមានអត្រាឆ្លងខ្ពស់ មានដូចជា ក្រុមបុរសស្រឡាញ់បុរស ក្រុមស្រីស្រស ក្រុមស្ត្រីធ្វើការកន្លែងកម្សាន្តសប្បាយ និងអ្នកប្រើប្រាស់គ្រឿងញៀន។

